**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរឃុំនៃរាជធានីភ្នំពេញទៅជាសង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល ដោយកាត់យកឃុំចំនួន ២០ នៃខេត្តកណ្តាលមកបញ្ចូលក្នុងរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានប្តូរឃុំចំណុះខណ្ឌសែនសុខ រាជធានីភ្នំពេញ មកជាសង្កាត់ មានដូចខាងក្រោម :

- ឃុំព្រែកព្នៅ ទៅជា សង្កាត់ព្រែកព្នៅ
- ឃុំសំរោង ទៅជា សង្កាត់សំរោង
- ឃុំពញាពន់ ទៅជា សង្កាត់ពញាពន់ ។

**មាត្រា ២.-**

ត្រូវបានប្តូរឃុំចំណុះខណ្ឌដង្កោ រាជធានីភ្នំពេញ មកជាសង្កាត់ មានដូចខាងក្រោម :

- ឃុំពន្សាំង ទៅជា សង្កាត់ពន្សាំង
- ឃុំស្នោរ ទៅជា សង្កាត់ស្នោរ
- ឃុំឪឡោក ទៅជា សង្កាត់ឪឡោក
- ឃុំបឹងធំ ទៅជា សង្កាត់បឹងធំ
- ឃុំកំបូល ទៅជា សង្កាត់កំបូល
- ឃុំកន្ទោក ទៅជា សង្កាត់កន្ទោក
- ឃុំគងនយ ទៅជា សង្កាត់គងនយ
- ឃុំទៀន ទៅជា សង្កាត់ទៀន
- ឃុំរលួស ទៅជា សង្កាត់រលួស
- ឃុំស្ពានថ្ម ទៅជា សង្កាត់ស្ពានថ្ម
- ឃុំព្រែកកំពឹស ទៅជា សង្កាត់ព្រែកកំពឹស ។

**មាត្រា ៣.-**

ត្រូវបានប្តូរឃុំចំណុះខណ្ឌមានជ័យ រាជធានីភ្នំពេញ មកជាសង្កាត់ មានដូចខាងក្រោម :

- ឃុំវាលស្បូវ ទៅជា សង្កាត់វាលស្បូវ
- ឃុំព្រែកឯង ទៅជា សង្កាត់ព្រែកឯង
- ឃុំក្បាលកោះ ទៅជា សង្កាត់ក្បាលកោះ
- ឃុំព្រែកថ្មី ទៅជា សង្កាត់ព្រែកថ្មី ។

**មាត្រា ៤.-**

ត្រូវបានប្តូរឃុំចំណុះខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ មកជាសង្កាត់ មានដូចខាងក្រោម :

- ឃុំបាក់ខែង ទៅជា សង្កាត់បាក់ខែង
- ឃុំកោះដាច់ ទៅជា សង្កាត់កោះដាច់ ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ អភិបាលខណ្ឌពាក់ព័ន្ធ និងចៅសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*